ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការបរទេស
និងសហប្រតិបត្តិការអន្តរជាតិ
នាយកដ្ឋានព័ត៌មាន

# សេចក្តីប្រកាសព័ត៌មាន
## ស្តីពីលទ្ធផលនៃដំណើរទស្សនកិច្ចផ្លូវការរបស់រដ្ឋមន្ត្រីការបរទេស នៃសាធារណរដ្ឋសិង្ហបុរី នៅព្រះរាជាណាចក្រកម្ពុជា
ថ្ងៃទី ១៧ ខែ តុលា ឆ្នាំ ២០១៧

-------------------------------

តបតាមការអញ្ជើញរបស់ឯកឧត្តម ប្រាក់ សុខុន ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីការបរទេស និងសហប្រតិបត្តិការអន្តរជាតិ នៃព្រះរាជាណាចក្រកម្ពុជា ឯកឧត្តមបណ្ឌិត វីវៀន បាឡាគ្រីស្សស្នាន (Vivian Balakrishnan) រដ្ឋមន្ត្រីការបរទេស នៃសាធារណរដ្ឋសិង្ហបុរី បានដឹកនាំគណៈប្រតិភូ អញ្ជើញមកបំពេញទស្សនកិច្ចផ្លូវការ នៅព្រះរាជាណាចក្រកម្ពុជា នៅថ្ងៃទី ១៧ ខែតុលា ឆ្នាំ២០១៧ ។

ក្នុងអំឡុងពេលទស្សនកិច្ចនេះ ឯកឧត្តមបណ្ឌិត វីវៀន បាឡាគ្រីស្សស្នាន បានចូលក្រាបបង្គំគាល់ព្រះករុណាព្រះបាទសម្តេច ព្រះបរមនាថ នរោត្តមសីហមុនី ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ។

ឯកឧត្តមបណ្ឌិត វីវៀន បាឡាគ្រីស្សស្នាន ក៏បានចូលជួបសំដែងការគួរសមជាមួយសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ដែលនៅក្នុងឱកាសនៃជំនួបនោះ សម្តេចតេជោនាយករដ្ឋមន្ត្រី បានធ្វើការវាយតំលៃខ្ពស់ចំពោះទំនាក់ទំនងដ៏យូរលង់រវាងប្រទេសទាំងពីរ ហើយដែលត្រូវបានថែទាំ ពូនជ្រំ ដោយអ្នកជំនាន់ក្រោយ។ សំខាន់ជាងនេះទៅទៀត សម្តេចតេជោ ក៏បានសម្តែងការពេញចិត្តចំពោះការរីកចំរើនក្នុងកិច្ចសហប្រតិបត្តិការទ្វេភាគីលើគ្រប់វិស័យដែលប្រទេសទាំងពីរកំពុងអនុវត្ត នាពេលបច្ចុប្បន្ននេះ។

ឯកឧត្តម វីវៀន បាឡាគ្រីស្សស្នាន បានមានកិច្ចប្រជុំទ្វេភាគីជាមួយឯកឧត្តមទេសរដ្ឋមន្ត្រី ប្រាក់ សុខុន ផងដែរ។ ក្នុងអំឡុងពេលកិច្ចប្រជុំ ដោយរំលឹកឡើងវិញពីដំណើរទស្សនកិច្ចផ្លូវរដ្ឋប្រកបដោយជោគជ័យ នៅកម្ពុជាកាលពីខែមករាឆ្នាំនេះ របស់ឯកឧត្តមបណ្ឌិត Tony Tan Keng Yam អតីតប្រធានាធិបតីនៃសាធារណរដ្ឋសិង្ហបុរី រដ្ឋមន្ត្រីការបរទេសទាំងពីររូប បានធ្វើការពិភាក្សាដោយស្មោះត្រង់ និងឯកភាពគ្នា ក្នុងការពង្រឹងបន្ថែមទៀតលើកិច្ចសហប្រតិបត្តការទ្វេភាគី លើវិស័យមួយចំនួន ដូចជា ពាណិជ្ជកម្ម និងការវិនិយោគ អប់រំ និងការអភិវឌ្ឍធនធានមនុស្ស ទេសចរណ៍ វប្បធម៌ ការងារ ការតភ្ជាប់

អាសយដ្ឋាន: លេខ ៣ វិថី សម្តេច ហ៊ុន សែន
សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ : (855) 23 214 441, 216 122
ទូរសារ : (855) 23 216 144, 216 141
អ៊ីម៉ែល : mfaic@mfa.gov.kh

ផ្លូវអាកាស និងសុខាភិបាល ព្រមទាំងបានផ្លាស់ប្តូរទស្សនវិស័យ លើបញ្ហាតំបន់ និងអន្តរជាតិ ដែលមានផលប្រយោជន៍ទៅវិញទៅមក។

ដើម្បីបង្កើនពាណិជ្ជកម្មទ្វេភាគីថែមទៀត ឯកឧត្តមទេសរដ្ឋមន្ត្រី បានស្នើឱ្យសិង្ហបុរី ពិចារណាក្នុងការនាំចូលផលិតផលកសិកម្ម ដូចជា អង្ករ ម្រេច ផ្លែស្វាយ សម្រាប់ទីផ្សារសិង្ហបុរី ។ បន្ថែមពីនេះ ឯកឧត្តមទេសរដ្ឋមន្ត្រី បានកត់សម្គាល់ជាមួយការពេញចិត្ត លើការចុះហត្ថលេខានៃកិច្ចព្រមព្រៀងលើវិស័យប្រេងកាត សម្រាប់ការអភិវឌ្ឍវិស័យប្រេងក្នុងដែនសមុទ្រ នៅក្នុងប្លុកA រវាងកម្ពុជា និងក្រុមហ៊ុនសិង្ហបុរី KrisEnergy ។ ឯកឧត្តមទេសរដ្ឋមន្ត្រី ក៏បានស្នើឱ្យសិង្ហបុរី ពង្រីកការវិនិយោគបន្ថែម ក្នុងវិស័យដែលមានសក្តានុពលផ្សេងទៀត ផងដែរ។

រដ្ឋមន្ត្រីទាំងពីរ បានកត់សម្គាល់លើកំណើននៃចំនួនភ្ញៀវទេសចរណ៍ ពីមួយឆ្នាំ ទៅមួយឆ្នាំ ដែលនឹងជម្រុញការប្រាស័យទាក់ទងគ្នារវាងប្រជាជននៃប្រទេសទាំងពីរ។ ឯកឧត្តមទេសរដ្ឋមន្ត្រី ក៏បានផ្តល់យោបល់ដែរថា ប្រទេសទាំងពីរគួរតែពង្រីកកិច្ចសហប្រតិបត្តិការ ក្នុងការទប់ស្កាត់ការជួញដូរខុសច្បាប់នូវសម្បត្តិវប្បធម៌។ ភាគីទាំងពីរ ក៏បានពិភាក្សាលើកិច្ចសហប្រតិបត្តិការក្នុងវិស័យអាកាសចរស៊ីវិល ផងដែរ។

ចំពោះកិច្ចសហប្រតិបត្តិការលើវិស័យការងារ ឯកឧត្តមទេសរដ្ឋមន្ត្រី បានសម្តែងអំណរគុណដល់រដ្ឋាភិបាលសិង្ហបុរី ចំពោះការទទួលយកពលករកម្ពុជា និងសង្ឃឹមថា ប្រទេសសិង្ហបុរី នឹងនៅតែបន្តស្វាគមន៍ពលករកម្ពុជា បន្ថែមទៀត។

ក្នុងគោលបំណងពង្រឹងកិច្ចសហប្រតិបត្តិការទ្វេភាគី រវាងក្រសួងការបរទេស នៃប្រទេសទាំងពីរ ឯកឧត្តមទេសរដ្ឋមន្ត្រី ប្រាក់ សុខុន និងឯកឧត្តមបណ្ឌិត វីវៀន បាឡាគ្រីស្សស្នាន បានចុះហត្ថលេខាលើអនុស្សារណៈយោគយល់គ្នារវាងក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ នៃព្រះរាជាណាចក្រកម្ពុជា និងក្រសួងការបរទេស នៃសាធារណរដ្ឋសិង្ហបុរី ស្តីពីការពិគ្រោះយោបល់ផ្នែកនយោបាយ។

គួរកត់សំគាល់ផងដែរថា ក្នុងអំឡុងពេលស្នាក់នៅប្រទេសកម្ពុជា ឯកឧត្តម វីវៀន បាឡាគ្រីស្សស្នាន ក៏បានជួបប្រជុំជាមួយឯកឧត្តមបណ្ឌិត អូន ព័ន្ធមុនីរ័ត្ន ទេសរដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងអញ្ជើញពិសារអាហារពេលល្ងាច រៀបចំដោយឯកឧត្តម សាយ សំអាល់ រដ្ឋមន្ត្រីក្រសួងបរិស្ថាន ផងដែរ។ នៅក្នុងជំនួបនោះ រដ្ឋមន្ត្រីបានធ្វើការពិភាក្សាដោយស្មោះត្រង់ និងស្និទ្ធស្នាល សំដៅរិះរកជំហានថ្មី ដើម្បីពង្រីកកិច្ចសហប្រតិបត្តិការទ្វេភាគី។

ភ្នំពេញ ថ្ងៃទី ១៨ ខែតុលា ឆ្នាំ ២០១៧